[ទំរង់បែបបទលេខ.11]

# លិខិតបញ្ជាក់ការលែងលះ(ការចាត់តាំងអ្នកមានសិទ្ធិជាមាតាបិតា)

( ឆ្នាំ. ខែ. ថ្ងៃ)

※ ចូរបំពេញបែបបទខាងក្រោម បន្ទាប់ពីអានការណែនាំនៅក្នុងទំព័រ ខាងក្រោយ។ កត់សំគាល់លេខដែលអ្នកបានជ្រើសរើស ដោយរង្វង់ មូល "○" សំរាប់លេខនីមួយៗ។

| ផ្នែក | | | ស្វាមី | | | ភរិយា | | |
|---|---|---|---|---|---|---|---|---|
| ① ភាគីលែងលះ (ភាគីដែលរាយការណ៍) | ឈ្មោះ | អក្សរកូរ៉េ | (ឈ្មោះ) /(ត្រកូល) | | ត្រា រឺហត្ថលេខា | (ឈ្មោះ) /(ត្រកូល) | | ត្រា រឺហត្ថលេខា |
| | | អក្សរចិន | (ឈ្មោះ) /(ត្រកូល) | | | (ឈ្មោះ) /(ត្រកូល) | | |
| | ដើមកំណើតត្រកូល(អក្សរចិន) | | | លេខ ទូរស័ព្ទ | | ដើមកំណើតត្រកូល(អក្សរចិន) | | លេខ ទូរស័ព្ទ |
| | លេខចុះបញ្ជីស្នាក់នៅ | | - | | | - | | |
| | ថ្ងៃខែឆ្នាំកំណើត | | | | | | | |
| | កន្លែងចុះបញ្ជីយោង | | | | | | | |
| | អាសយដ្ឋាន | | | | | | | |
| ② កម្ពាយ (ឪពុកម្តាយចិញ្ចឹម) | ឈ្មោះឪពុក(ឪពុកចិញ្ចឹម) | | | | | | | |
| | លេខចុះបញ្ជីស្នាក់នៅ | | - | | | - | | |
| | ឈ្មោះម្តាយ(ម្តាយចិញ្ចឹម) | | | | | | | |
| | លេខចុះបញ្ជីស្នាក់នៅ | | - | | | - | | |
| ③ ផ្សេងៗ | | | | | | | | |
| ④ កាលបរិច្ឆេទកាត់សេចក្តី ( ) | | | ឆ្នាំ. ខែ. ថ្ងៃ | | | ឈ្មោះ តុលាការ | តុលាការ | |

ផ្នែកចាត់តាំងអាណាព្យាបាលខាងក្រោមនេះ ត្រូវបំពេញបន្ទាប់ពីតុលាការបានកាត់សេចក្តីចំពោះគោលបំណងនៃការលែងលះ ក្នុងករណីដែលធ្វើការលែងលះដោយព្រមព្រៀង

| | | | | | | | |
|---|---|---|---|---|---|---|---|
| ⑤ ការចាត់តាំងអ្នកមានសិទ្ធិជាមាតាបិតា | ឈ្មោះអនីតិជន | | | | | | |
| | លេខចុះបញ្ជីស្នាក់នៅ. | - | | | - | | |
| | អាណាព្យាបាល | 1ឪពុក 2ម្តាយ 3ឪពុកម្តាយ | សុពលភាព | ឆ្នាំ. ខែ. ថ្ងៃ | 1ឪពុក 2ម្តាយ 3ឪពុកម្តាយ | សុពលភាព | ឆ្នាំ. ខែ. ថ្ងៃ |
| | | | មូលហេតុ | 1ព្រមព្រៀង 2ជំនុំជំរះ | | មូលហេតុ | 1ព្រមព្រៀង 2ជំនុំជំរះ |
| | ឈ្មោះអនីតិជន | | | | | | |
| | លេខចុះបញ្ជីស្នាក់នៅ | - | | | - | | |
| | អាណាព្យាបាល | 1ឪពុក 2ម្តាយ 3ឪពុកម្តាយ | សុពលភាព | ឆ្នាំ. ខែ. ថ្ងៃ | 1ឪពុក 2ម្តាយ 3ឪពុកម្តាយ | សុពលភាព | ឆ្នាំ. ខែ. ថ្ងៃ |
| | | | មូលហេតុ | 1ព្រមព្រៀង 2ជំនុំជំរះ | | មូលហេតុ | 1ព្រមព្រៀង 2ជំនុំជំរះ |
| ⑥ វត្តមានរបស់ភាគីរាយការណ៍ | | 1 ស្វាមី 2 ភរិយា | | | | | |
| ⑦ ដាក់ជូនដោយ | ឈ្មោះ | | | លេខចុះបញ្ជីស្នាក់នៅ | - | | |

※ បុគ្គលណា ដែលធ្វើការរាយការណ៍មិនត្រឹមត្រូវ ដោយប្រើប្រាស់ហត្ថលេខា រឺត្រា របស់អ្នកដទៃ រឺបានរាយការណ៍នូវព័ត៌មានមិនពិតនៅក្នុង ការចុះបញ្ជីទំនាក់ទំនងគ្រួសារ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង 5 ឆ្នាំ រឺផាកពិន័យតិចជាង ១០ លានវ៉ុន ដោយយោង ទៅតាមច្បាប់ព្រហ្មទណ្ឌ។

※ សូមបំពេញព័ត៌មានខាងក្រោមអោយបានត្រឹមត្រូវ ព្រោះទិន្នន័យដែលត្រូវការ នឹងត្រូវប្រើប្រាស់សំរាប់បង្កើតគោលការណ៍ផ្សេងៗ សំរាប់ ប្រជាជន ហើយអ្នកត្រូវបំពេញអោយបានត្រឹមត្រូវ ដោយយោងទៅតាមមាត្រាទី 32 និង 33 នៃច្បាប់ស្ថិតិ ហើយព័ត៌មានផ្ទាល់ខ្លួន របស់អ្នកនឹងត្រូវបានរក្សាការសំងាត់។

| | | | | | |
|---|---|---|---|---|---|
| ⑧កាលបរិច្ឆេទរៀបអាពាហ៍ ពិពាហ៍ពិតប្រាកដ (រស់នៅជាមួយគ្នា) | | ចាប់តាំងពី ឆ្នាំ. ខែ. ថ្ងៃ | ⑨កាលបរិច្ឆេទលែងលះ ពិតប្រាកដ | | ចាប់តាំងពី ឆ្នាំ. ខែ. ថ្ងៃ |
| ⑩ ចំនួនកូនដែលមានអាយុ ក្រោម 20 ឆ្នាំ | | នាក់ | ⑪ ប្រភេទលែងលះ | | 1លែងលះដោយព្រមព្រៀង 2លែងលះដោយជំនុំជំរះ |
| ⑫ មូលហេតុនៃការលែងលះ (ជ្រើសរើសមួយ) | 1 ស្វាមី រឺភរិយាមានការក្បត់ 2 អំពើហិង្សាលើរាងកាយ ស្មារតី 3 គ្រួសារមិនចុះសម្រុងគ្នា 4 បញ្ហាសេដ្ឋកិច្ច 5 ចរិតខុសគ្នា 6បញ្ហាសុខភាព 7ផ្សេងៗ | | | | |
| ⑬ សញ្ជាតិ | ស្វាមី | 1 កូរ៉េ (សញ្ជាតិពីកំណើត)<br>2 កូរ៉េ [ចូលសញ្ជាតិ (រួមមានសញ្ជាតិពីរ). ការទទួលបានសញ្ជាតិ សញ្ជាតិដើម : ]<br>3ជនបរទេស (សញ្ជាតិ ) | ភរិយា | 1 កូរ៉េ (សញ្ជាតិពីកំណើត)<br>2 កូរ៉េ [ចូលសញ្ជាតិ (រួមមានសញ្ជាតិពីរ). ការទទួលបានសញ្ជាតិ សញ្ជាតិដើម : ]<br>3ជនបរទេស (សញ្ជាតិ ) | |
| ⑭ការអប់រំចុងក្រោយ | ស្វាមី | 1មិនមាន 2បឋមសិក្សា 3អនុវិទ្យាល័យ 4វិទ្យាល័យ 5មហា(សាកល)វិទ្យាល័យ 6 អនុបណ្ឌិត រឺខ្ពស់ជាង | ភរិយា | 1មិនមាន 2បឋមសិក្សា 3អនុវិទ្យាល័យ 4វិទ្យាល័យ 5មហា(សាកល)វិទ្យាល័យ 6 អនុបណ្ឌិត រឺខ្ពស់ជាង | |
| ⑮ មុខរបរ | ស្វាមី | 1អ្នកគ្រប់គ្រង 2អ្នកជំនាញ និងអ្នកធ្វើការពាក់ពន្ធនឹងឯកទេស<br>3ជំនួយការការិយាល័យ 4អ្នកធ្វើការផ្នែកសេវាកម្ម<br>5អ្នកធ្វើការផ្នែកលក់<br>6អ្នកជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>7ជាងម៉ាស៊ីន និងបុគ្គលិកជំនាញ<br>8បុគ្គលិកប្រើប្រាស់ឧបករណ៍រោងចក្រ ម៉ាស៊ីន និងអ្នកតំឡើង<br>9កម្មករ 10និស្សិត 11មេផ្ទះ 12ទាហាន 13មិនមាន | ភរិយា | 1អ្នកគ្រប់គ្រង 2អ្នកជំនាញ និងអ្នកធ្វើការពាក់ពន្ធនឹងឯកទេស<br>3ជំនួយការការិយាល័យ 4អ្នកធ្វើការផ្នែកសេវាកម្ម<br>5អ្នកធ្វើការផ្នែកលក់<br>6អ្នកជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>7ជាងម៉ាស៊ីន និងបុគ្គលិកជំនាញ<br>8បុគ្គលិកប្រើប្រាស់ឧបករណ៍រោងចក្រ ម៉ាស៊ីន និងអ្នកតំឡើង<br>9កម្មករ 10និស្សិត 11មេផ្ទះ 12ទាហាន 13មិនមាន | |

# ការណែនាំរបៀបបំពេញបែបបទ

※ កន្លែងចុះបញ្ជីយោងៈ បំពេញនូវសញ្ជាតិ ប្រសិនបើអ្នកដែលបំពេញបែបបទនេះជាជនបរទេស។

※ លេខចុះបញ្ជីស្នាក់នៅ. ៈ បំពេញលេខចុះបញ្ជីសំរាប់ជនបរទេស (លេខរាយការណ៍កន្លែងចុះបញ្ជីស្នាក់នៅក្នុងស្រុក រឺថ្ងៃខែឆ្នាំកំណើត) ប្រសិនបើអ្នកដែលបំពេញបែបបទនេះជាជនបរទេស។

ផ្នែក①ៈ ភាគីទាំងសងខាងត្រូវចុះហត្ថលេខា (រឺប្រថាប់ត្រា) ក្នុងករណីដែលធ្វើការលែងលះដោយព្រមព្រៀង តែក្នុងករណីដែល ធ្វើការលែងលះដោយជំនុំជំរះភាគីម្ខាង អាចធ្វើការចុះហត្ថលេខា (រឺប្រថាប់ត្រា) ដើម្បីធ្វើការប្រកាសលែងលះដោយភាគីតែម្ខាងបាន។

ផ្នែក②ៈ ក្នុងករណីដែលឪពុកម្តាយនៃភាគីដែលលែងលះ មិនមានលេខចុះបញ្ជីស្នាក់នៅ អាចបំពេញទីកន្លែងមូលដ្ឋានចុះបញ្ជីយោង ទីកន្លែងមូលដ្ឋានចុះបញ្ជីគ្រួសារ(ដើមកំណើត) បានក្នុងករណីដែលភាគីលែងលះ គឺជាកូនចិញ្ចឹម ត្រូវបំពេញព័ត៌មានផ្ទាល់ខ្លួននៃឪពុកម្តាយចិញ្ចឹម ក្នុងករណីឪពុកម្តាយនៃភាគីលែងលះជាជនបរទេស ត្រូវបំពេញលេខចុះបញ្ជីស្នាក់នៅជនបរទេស (រឺថ្ងៃខែឆ្នាំកំណើត) ក្នុងផ្នែក លេខចុះបញ្ជីស្នាក់។

ផ្នែក③ៈ បំពេញព័ត៌មានខាងក្រោម ជាមួយនឹងខ្លឹមសារដែលត្រូវការសំរាប់ធ្វើការចុះបញ្ជីទំនាក់ទំនងគ្រួសារអោយបានច្បាស់លាស់។
- ឈ្មោះ ថ្ងៃខែឆ្នាំកំណើត កន្លែងចុះបញ្ជីយោង និងមូលហេតុនៃការផ្លាស់ប្តូរស្ថានភាព ក្នុងករណីភាគីមានការផ្លាស់ប្តូរពេល ប្រកាសការលែងលះ។
- ឈ្មោះ ហត្ថលេខា (រឺត្រា) និងថ្ងៃខែឆ្នាំកំណើតនៃភាគីដែលយល់ព្រម នៅពេលដែលបុគ្គលដែលមិនមានសមត្ថភាពធ្វើការ លែងលះដោយព្រមព្រៀង។

ផ្នែក④ៈ បំពេញចំពោះករណីលែងលះដោយជំនុំជំរះ (ការសំរុះសំរួល ការផ្សះផ្សាលេខចុះបញ្ជីស្នាក់នៅ ) និងមិនមែនជាករណីដែលលែងលះដោយព្រមព្រៀង។
ៈក្នុងករណីដែលប្រកាសលែងលះ ដោយយោងទៅតាមការសំរេចនៃការជំនុំជំរះ ទាមទារអោយមានការកែប្រែ សេចក្តីសំរេចត្រូវបានចាត់ទុកជាការសំរេចជំនួសការកែប្រែ រឺសេចក្តីសំរេចដែលសុំអោយសំរបសំរួល សូមបំពេញចន្លោះ (　　) ខាងក្រោម "ការកាត់សេចក្តីបានសំរេចថា "បានសំរេចសំរបសំរួល" "បានសំរេចបញ្ជាក់ដូចជាការសំរបសំរួល" រឺ "សំរេចបានផ្សះផ្សាគ្នា" "បានសំរេចអនុសាសន៍ផ្សះផ្សា" ជាមួយនឹងកាលបរិច្ឆេទនៃការសំរេច (កាត់សេចក្តី) នៅក្នុងផ្នែក "ឆ្នាំ/ខែ/ថ្ងៃ"។

ផ្នែក⑤ៈ មិនបាច់បំពេញផ្នែកនេះ ក្នុងករណីដែលដាក់ពាក្យដើម្បីប្រកាសការលែងលះដោយព្រមព្រៀង
ប៉ុន្តែត្រូវបំពេញផ្នែកចាត់តាំងអ្នកមានសិទ្ធិជាមាតាបិតាបន្ទាប់ពីតុលាការធ្វើការសំរេចអំពីគោលបំណងនៃការលែងលះ។ ចាប់ពីថ្ងៃចាប់ផ្តើមសុពលភាព ត្រូវបំពេញ កាលបរិច្ឆេទរាយការណ៍លែងលះ ក្នុងករណីដែលលែងលះដោយព្រមព្រៀង រឺកាលបរិច្ឆេទជំនុំជំរះក្នុងករណីដែលលែងលះដោយ ជំនុំជំរះ។ សំរាប់ផ្នែកមូលហេតុ ត្រូវគូសរង្វង់ "○" សំរាប់ពាក្យ "ព្រមព្រៀង" ក្នុងករណីដែលភាគីពាក់ព័ន្ធបានយល់ព្រមលែងលះ និងពាក្យ "ជំនុំជំរះ" ក្នុងករណីការលែងលះសំរេចដោយតុលាការ រឺការដាក់ពាក្យលែងលះ ត្រូវតែភ្ជាប់នូវឯកសារបញ្ជាក់អំពី ខ្លឹមសារ។ ក្នុងករណីដែលមានកូនលើសពី 3 នាក់ ត្រូវភ្ជាប់ឯកសារបន្ថែម និងភ្ជាប់ជាមួយពាក្យសុំ ដោយធ្វើការប្រថាប់ត្រានៅលើ ទំព័រនីមួយៗ។ ក្នុងករណីដែលភាគីស្ត្រីមានផ្ទៃពោះ ការចាត់តាំងអ្នកមានសិទ្ធិជាមាតាបិតាត្រូវប្រកាសនៅពេលដែលចុះបញ្ជីសំរាលកូន។

ផ្នែក⑥ៈ គូសរង្វង់ "○" ក្នុងករណីដែលភាគីរាយការណ៍មានវត្តមាន។

ផ្នែក⑦ៈ បំពេញឈ្មោះ និងលេខចុះបញ្ជីស្នាក់នៅ នៃភាគីដាក់ពាក្យ (ដោយមិនគិតថាអ្នកនោះជាភាគីរាយការណ៍រឺអត់) [មន្ត្រីរដ្ឋាភិបាលទទួល បន្ទុកទទួល និងត្រួតពិនិត្យអត្តសញ្ញាណប័ណ្ណ].

ផ្នែក⑧ និង ⑨ៈ បំពេញកាលបរិច្ឆេទជាក់លាក់នៃការចាប់ផ្តើមអាពាហ៍ពិពាហ៍ (រស់នៅជាមួយគ្នា) និងកាលបរិច្ឆេទជាក់លាក់នៃការលែងលះ (រស់នៅបែកគ្នា) ដោយមិនគិតអំពីកាលបរិច្ឆេទប្រកាសទំនាក់ទំនងគ្រួសារ រឺកាលបរិច្ឆេទកាត់ក្តី។

ផ្នែក⑭ៈ បំពេញនូវស្ថាប័នអប់រំ ដែលទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា។ ក៏ប៉ុន្តែ សំរាប់អ្នកដែលកំពុងរៀន រឺឈប់រៀន នៅក្នុងកំរិត នីមួយៗ ត្រូវគូសរង្វង់សំគាល់ "○" សំរាប់បង្ហាញអំពីចំលើយនៃកំរិតអប់រំចុងក្រោយបំផុត ដែលបាន បញ្ចប់។
<ឧ> កំពុងរៀន (ឈប់រៀន) ឆ្នាំទីមួយនៃមហាវិទ្យាល័យ ៈ គូសរង្វង់មូល "○" សំរាប់វិទ្យាល័យ។

ផ្នែក⑮ៈ បំពេញអំពីមុខរបរចំបងនៅពេលលែងលះ។

1 អ្នកគ្រប់គ្រងៈ រៀបចំគំរោង ដឹកនាំ និងកែប្រែគោលការណ៍ និងសកម្មភាពផ្សេងៗសំរាប់រដ្ឋាភិបាល សហគ្រាស រឺក្រុមការងារផ្ទៃក្នុង (មន្ត្រី សាធារណៈ រឺបុគ្គលិកជាន់ខ្ពស់ក្នុងផ្នែកសហគ្រាស)។

2 អ្នកជំនាញ និងអ្នកបច្ចេកទេសៈ បំពេញការងារបច្ចេកទេស ដោយប្រើប្រាស់ចំនេះដឹងជំនាញ (វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ អប់រំ សាសនា ច្បាប់ ហិរញ្ញវត្ថុ សិល្បៈ និងកីឡាជាដើម)។

3 ជំនួយការៈ បំពេញការងារដែលជួយដល់នាយក អ្នកជំនាញ និងអ្នកបច្ចេកទេស (ផ្នែកគ្រប់គ្រង ធានារ៉ាប់រង សវនកម្ម ប្រឹក្សា ណែនាំ　ផ្នែកស្ថិតិជាដើម)។

4 បុគ្គលិកផ្នែកសេវាកម្ម ៈ ប្រកបអាជីវកម្មពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈ ការគាំពារ ជំនួយការផ្នែកវេជ្ជសាស្ត្រ ជាងធ្វើសក់ អ្នកបំពេញ ការងារទាក់ទងនឹងអាពាហ៍ពិពាហ៍ និងបុណ្យសព ការដឹកជញ្ជូន ការកំសាន្ត និងចំអិនអាហារ។

5 អ្នកអាជីវកម្មផ្នែកលក់ ៈ ពាក់ព័ន្ធនឹងការលក់ផលិតផល រឺសេវាកម្ម (តាមអ៊ីនធើណែត ហាង និងកន្លែងសាធារណៈជាដើម) ការឃោសនានិងការផ្សព្វផ្សាយផលិតផលរឺទំនិញ ជាដើម។

6 អ្នកជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៈ បំពេញការងារពាក់ព័ន្ធនឹងការដាំដុះ និងការចិញ្ចឹមសត្វ ការបណ្តុះ និងការដាំកូនឈើ ការបំពេញការងារពាក់ព័ន្ធនឹងសត្វព្រៃ និងព្រៃឈើ ការដាំដុះ និងបង្កបង្កើនផលដំណាំជាដើម។

7 ជាង និងបុគ្គលិកជំនាញៈ បំពេញការងារតំឡើងម៉ាស៊ីន និងជួសជុលម៉ាស៊ីនៈដោយប្រើឧបករណ៍ផ្សេងៗនិងដៃផ្ទាល់ នៅក្នុងឧស្សាហកម្ម រ៉ែ វាយនភ័ណ្ឌ និងសំណង់ ក៏ដូចជាការផលិតក្រណាត់ជាដើម។

8 បុគ្គលិកប្រើប្រាស់ឧបករណ៍រោងចក្រ ម៉ាស៊ីន និងអ្នកតំឡើងៈ ផលិត តំឡើងផលិតផលដោយប្រើម៉ាស៊ីន គ្រប់គ្រងម៉ាស៊ីនដោយកុំព្យូទ័រ និងគ្រប់គ្រងដំណើរការរបស់មធ្យោបាយធ្វើដំណើរជាដើម ។

9 កម្មករៈ បំពេញការងារដែលទាមទារអោយប្រើប្រាស់ឧបករណ៍ងាយៗ ប្រចាំថ្ងៃ និងកំលាំងបាយ។

11 មេផ្ទះ ៈ បំពេញការងារផ្ទះពេញមួយថ្ងៃ។　12 ទាហានៈទាហានអាជីព ដោយមិនរាប់បញ្ចូលសេនា រឺបុគ្គលដែលកំពុងបំពេញកាតព្វកិច្ចក្នុងយោធា។　13 មិនមានៈ មិនមានមុខរបរជាក់លាក់។

# ឯកសារភ្ជាប់

1. លែងលះដោយព្រមព្រៀងៈ លិខិតថតចំលងបញ្ជាក់អំពីការចង់លែងលះដែលមានការបញ្ជាក់ត្រឹមត្រូវ 1 ច្បាប់។
2. លែងលះដោយជំនុំជំរៈៈ លិខិតថតចំលង កាត់ក្តី និងលិខិតបញ្ជាក់ប្រកាសស្ថាពរនីមួយៗ 1 ច្បាប់ (លិខិតថតចំនិងលិខិតបញ្ជាក់បញ្ជូនក្នុងករណីបានសំរេចការសំរបសំរួលរឺផ្សះផ្សា )។
3. លែងលះដោយជំនុំជំរះ ដោយការសំរេចនៃតុលាការនៅបរទេស
- ច្បាប់ដើមប្រកាសនិងសេចក្តីថតចំលងនៃច្បាប់ដើម និងលិខិតបញ្ជាក់អំពីការសំរេចរបស់តុលាការ នីមួយៗ1 ច្បាប់។
- លិខិតដែលបញ្ជាក់អំពីអ្នកជាប់ចោទបានទទួលដីកាកោះ រឺការផ្ញើជូនសេចក្តីសំរេច ដែលទាមទារអោយមានការដាក់ពាក្យបណ្តឹង ដោយមិនធ្វើតាមរយៈការជូនដំណឹងជាសាធារណៈ រឺអ្នកជាប់ចោទមិនបាន ទទួលលិខិតជូនដំណឹង។ ក្នុងករណីដែលអ្នកជាប់ចោទ ដែលបរាជ័យ គឺជាជនជាតិកូរ៉េ 1 ច្បាប់ (គ្រាន់តែចំពោះករណីដែលចំណុចនោះមិនច្បាស់ ទោះជាកាត់ក្តីហើយក៏ដោយ)។
- លិខិតបកប្រែនៃឯកសារខាងលើទាំងអស់ មួយមុខ 1 ច្បាប់។

**※ ការភ្ជាប់ឯកសារក្នុងផ្នែកទី 4 ខាងក្រោម អាចនឹងលុបចោល ក្នុងករណីដែលខ្លឹមសារនេះអាចបញ្ជាក់បានតាមរយៈ ទិន្នន័យ ដែល មាននៅក្នុងការិយាល័យរដ្ឋបាលសំរាប់ការចុះបញ្ជីទំនាក់ទំនងគ្រួសារ។**

4. លិខិតបញ្ជាក់ទំនាក់ទំនងគ្រួសារ និងលិខិតបញ្ជាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍នៃការចុះបញ្ជីទំនាក់ទំនងគ្រួសារសំរាប់ភាគីលែងលះ នីមួយៗ មួយមុខ 1 ច្បាប់។
5. ក្នុងករណីដែលភាគីសាមីខ្លួន គឺជាជនបរទេស
- លែងលះតាមរបៀបកូរ៉េៈ ឯកសារច្បាប់ដើមដែលបញ្ជាក់អំពីសញ្ជាតិក្នុងករណីលែងលះដោយព្រមព្រៀង ច្បាប់ថតចំលងនៃឯកសារ បញ្ជាក់អំពីសញ្ជាតិ (លិខិតឆ្លងដែន រឺលិខិតចុះបញ្ជីជនបរទេស) មួយមុខ 1 ច្បាប់ ក្នុងករណីលែងលះដោយជំនុំជំរះ។
- លែងលះតាមរបៀបបរទេសៈ លិខិតថតចំលងនៃការលែងលះដែលមានការបញ្ជាក់ត្រឹមត្រូវ ច្បាប់ថតចំលងនៃឯកសារ បញ្ជាក់អំពី សញ្ជាតិ (លិខិតឆ្លងដែន រឺលិខិតចុះបញ្ជីជនបរទេស) មួយមុខ 1 ច្បាប់។
6. ឯកសារបញ្ជាក់ពាក់ពន្ធនឹងការចាត់តាំងអ្នកមានសិទ្ធិជាមាតាបិតា
- ច្បាប់ថតចំលងដែលមានការបញ្ជាក់ត្រឹមត្រូវនៃការចាត់តាំងអាណាព្យាបាល ក្នុងករណីលែងលះដោយព្រមព្រៀង 1 ច្បាប់
- ច្បាប់ដើមនៃសេចក្តីសំរេចរបស់តុលាការ និងលិខិតបញ្ជាក់ប្រការទោសក្នុងករណីដែលតុលាការបានចេញសេចក្តីសំរេចនីមួយៗ 1 ច្បាប់
7. ការបញ្ជាក់អត្តសញ្ញាណ [យោងទៅតាមលេខ 23 នៃវិន័យបឋមក្នុងការចុះបញ្ជីទំនាក់ទំនងគ្រួសារ]

① ប្រកាសការលែងលះដោយជំនុំជំរះ (រួមទាំងច្បាប់ថតចំលងលិខិតប្រកាសលែងលះដែលមានការបញ្ជាក់ត្រឹមត្រូវ)
- នៅពេលដែលអ្នកចុះបញ្ជីមានវត្តមាន ៈ អត្តសញ្ញាណប័ណ្ណ
- នៅពេលដែលអ្នកដាក់ពាក្យមានអវត្តមានៈ អត្តសញ្ញាណប័ណ្ណរបស់អ្នកដាក់ពាក្យ
- នៅពេលដែលដាក់ពាក្យតាមប្រៃសនីយ៍ ៈ ច្បាប់ថតចំលងនៃអត្តសញ្ញាណប័ណ្ណរបស់អ្នករាយការណ៍លែងលះ

② ប្រកាសការលែងលះដោយព្រមព្រៀង
- នៅពេលដែលអ្នកប្រកាសមានវត្តមាន ៈ អត្តសញ្ញាណប័ណ្ណរបស់ភាគីប្រកាសលែងលះម្ខាង
- នៅពេលដែលអ្នកប្រកាសអវត្តមាន និងអ្នកដាក់ជូនមានវត្តមានៈ អត្តសញ្ញាណប័ណ្ណរបស់អ្នកដាក់ជូន និង អត្តសញ្ញាណប័ណ្ណរបស់ ភាគីប្រកាសម្ខាង រឺលិខិតបញ្ជាក់ហត្ថលេខាពិតប្រាកដ រឺលិខិតបញ្ជាក់ត្រា (ហត្ថលេខាដែលមានបញ្ជាក់សាការី ក្នុងករណី ដែលភាគីចុះបញ្ជីចុះហត្ថលេខានៅលើលិខិតចុះបញ្ជី ដោយមិនមានភ្ជាប់អត្តសញ្ញាប័ណ្ណរបស់ភាគីចុះបញ្ជី រឺលិខិតបញ្ជាក់ត្រា ក្នុងករណីប្រើប្រាស់ត្រានៅលើលិខិតចុះបញ្ជី)
- នៅពេលដែលដាក់ពាក្យតាមប្រៃសនីយ៍ ៈ លិខិតបញ្ជាក់លើហត្ថលេខាពិតប្រាកដ រឺលិខិតបញ្ជាក់ត្រា របស់ភាគីម្ខាង (លិខិតបញ្ជាក់ហត្ថលេខា ក្នុងករណីដែលចុះហត្ថលេខា រឺលិខិតបញ្ជាក់ត្រា ក្នុងករណីប្រើប្រាស់ត្រា)